ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ ...០៣៩.សជណ...../គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីជម្រើសនានាក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង នៅរដ្ឋបាលរាជធានី ខេត្ត និងរៀបចំនីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**(គ.ជ.អ.ប.)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩/០៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- យោងលិខិតចាត់តាំងសមាសភាពចូលរួមក្នុងក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាពីជម្រើសនានាក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត និងរៀបចំនីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ចាន់ សុផា** | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាប្រធាន |
| ២. **ឯកឧត្តម ជ័យ សម្បត្តិផល្លា** | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាអនុប្រធាន |
| ៣. **ឯកឧត្តមបណ្ឌិត ឳ សុវណ្ណ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤. **លោកជំទាវ ង៉ែត ម៉ូវីឡៀន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥. **ឯកឧត្តម ឈូក បណ្ឌិត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៦. **លោកឧត្តមសេនីយ៍ទោ ព្រុំ វុទ្ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៧. **លោក យ៉ុំ ម៉េងស៊ាន** | ប្រធានក្រុមសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាអនុប្រធាន |
| ៨. **លោក សរ គីនីរ៉ា** | ទីប្រឹក្សា ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩. **លោក ថាច់ សាវី** | ទីប្រឹក្សា នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១០. **លោក ម៉ឹង សេរី** | ទីប្រឹក្សា នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១១. **លោក សួន វិចិត្រ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាសមាជិក |
| ១២. **លោក វ៉ុំង សិរីរតនៈ** | ប្រធាននាយកដ្ឋានសវនកម្មទី២ នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៣. **លោក គឹមសួគ៌ តេតង់** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ១៤. **លោក សារ៉ូ រដ្ឋជាតិ** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ | ជាសមាជិក |

| | | |
|---|---|---|
| ១៥. **លោក ទើង សុភា** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ១៦. **លោក ឧត វណ្ណៈ** | អនុប្រធានក្រុមសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១៧. **លោក ឡុង រិទ្ធី** | អនុប្រធានក្រុមសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក |
| ១៨. **លោក ផន ចាន់ដារ៉ា** | អនុប្រធានអធិការកិច្ច នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាសមាជិក |
| ១៩. **លោក ហ៊ុំ ឆារ៉ា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ២០. **លោកស្រី សយ សារ៉េត** | ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល រាជធានី ខណ្ឌ និងខេត្ត ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២១. **លោក អាំង ណុបផាស៊ី** | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាលសរុប ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២២. **លោកស្រី ម៉ាង ឆយី** | ប្រធានការិយាល័យ នៃនាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២៣. **លោក ថន សីលា** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

**ប្រការ ២._**

ក្រុមការងារអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពរបស់ក្រុមការងារអំពីដំណើរការនៃការសិក្សា និងការរៀបចំលិខិតបទដ្ឋាននានា
- សិក្សាស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធ មុខងារ អធិការកិច្ច និងសវនកម្ម និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា និងវិភាគមុខងារសវនកម្មរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់រវាងតួនាទីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសវនកម្មផ្ទៃក្នុងនៅក្រសួង ស្ថាប័នថ្នាក់ជាតិ
- រៀបចំរបាយការណ៍សិក្សា និងផ្តល់ជាជម្រើសសម្រាប់បង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ជូនប្រធាន គ.ជ.អ.ប.
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើរបាយការណ៍ជម្រើសនានានៃការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងនីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង។ល។

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តក្នុងការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ជូនប្រធាន គ.ជ.អ.ប. ពិនិត្យ និងសម្រេច
- រៀបចំសេចក្តីណែនាំអំពីនីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៅថ្នាក់ក្រុង ស្រុក
- បំពេញតួនាទី ភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធាន គ.ជ.អ.ប.។

**ប្រការ ៣.**_

សមាជិកក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់មន្ត្រី ទីប្រឹក្សា ឧបករណ៍ សម្ភារៈ និងថវិការបស់ក្រសួង ស្ថាប័នសាមីនីមួយៗសម្រាប់ការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។

ក្រុមការងារអន្តរក្រសួងនេះអាចអញ្ជើញក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងដំណើការសិក្សា និងផ្តល់ជាធាតុចូលបន្ថែម ដើម្បីឱ្យការសិក្សា និងការរៀបចំរបាយការណ៍សិក្សាបានគ្រប់ជ្រុងជ្រោយ។

**ប្រការ ៤.**_

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប. និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ